ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៧ ស.ស.រ

សេចក្តីសំរេច

ស្តីពី

ការកែសំរួលសមាសភាពក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញសេចក្តីសំរេចលេខ ៣៤ ស.ស.រ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ
- បានឃើញសេចក្តីសំរេចលេខ ៤២ ស.ស.រ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- តាមការចាំបាច់ចំពោះមុខរបស់រាជរដ្ឋាភិបាល

សំរេច

ប្រការ១ .-

ត្រូវបានកែសំរួលសមាសភាព ក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ ដែលមានចែងក្នុងប្រការ១ នៃសេចក្តីសំរេចលេខ ៣៤ ស.ស.រ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុម

ការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ ដូចតទៅ :

១-ឯកឧត្តម វេង សេរីវុឌ្ឍ	ទេសរដ្ឋមន្ត្រី	ប្រធាន
២-ឯកឧត្តម ឡាយ ប្រហាស	រដ្ឋមន្ត្រីក្រសួងទេសចរណ៍	អនុប្រធាន
៣-ឯកឧត្តម ថោង ខុន	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធានប្រចាំការ
៤-ឯកឧត្តម សួស គង់	រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ	អនុប្រធាន
៥- ឯកឧត្តម សុន គន្ធរ	អគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ	សមាជិក
៦-ឯកឧត្តម ជុច ភឿន	រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក
៧-ឯកឧត្តម ឡុង វិសាលោ	រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ	សមាជិក
៨-ឯកឧត្តម ម៉ុន សម	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៩-ឯកឧត្តម ខៀវ មុត	រដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
១០-ឯកឧត្តម នុត ណារ៉ាង	រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
១១-ឯកឧត្តម តេង ឡៅ	រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
១២-ឯកឧត្តម វ៉េង សាខុន	រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម	សមាជិក
១៣-ឯកឧត្តម ញ៉ឹក ច្រឹង	រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
១៤-ឯកឧត្តម អ៊ឹង ភិរុន	រដ្ឋលេខាធិការក្រសួងសុខាភិបាល	សមាជិក
១៥-ឯកឧត្តម ភឹម ស៊ីថន	រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	សមាជិក
១៦-ឯកឧត្តម ថាច់ ផែន	រដ្ឋលេខាធិការក្រសួងព័ត៌មាន	សមាជិក
១៧-ឯកឧត្តម សារ៉ាក់ ខាន់	រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	សមាជិក
១៨-ឯកឧត្តម ខឹម ពិសិដ្ឋ	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
១៩-ឯកឧត្តម អ៊ឹក សារមេត្ត	អគ្គនាយករងអាជ្ញាធរអប្សរា	សមាជិក
២០-ឯកឧត្តម សូ ម៉ារ៉ា	អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍	ប្រធានក្រុមលេខាធិការ និងជាសមាជិក
២១-លោក ញឹម ខេមរា	ជំនួយការឯកឧត្តមទេសរដ្ឋមន្ត្រី វេង សិរីវុឌ្ឍ	លេខាធិការ

ប្រការ២ ..

ក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសំរួលការងារ ។

ប្រការ៣ ..

លេខាធិការដ្ឋាន នៃក្រុមការងារទេសចរណ៍សំរាប់កាត់បន្ថយភាពក្រីក្រ មានទីតាំងនៅទីស្តីការ-គណៈរដ្ឋមន្ត្រី ។

ប្រការ៤ ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៥ ..

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន និងអភិបាលខេត្ត-ក្រុង ពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -គ្រប់ក្រសួង ស្ថាប័ន
- -ដូចប្រការ៥
- -ឯកសារ-កាលប្បវត្តិ